ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ស្តង់ដានាយកសាលារៀន

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
ឆ្នាំ ២០១៧

# មុខកថា

គោលនយោបាយស្តីពីគ្រូបង្រៀនបានកំណត់អំពីចក្ខុវិស័យ កសាងគ្រូបង្រៀនឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈ ដោយមានការទទួលស្គាល់ពីសង្គម។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញយុទ្ធសាស្ត្រជាច្រើន ក្នុងនោះក៏មានការពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន។ ក្នុងក្របខ័ណ្ឌផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន ត្រង់ចំណុច ៨.១.១.២ សំដៅបង្កើតស្តង់ដានាយកសាលារៀន។

គុណភាពអប់រំគឺជាគុណភាពគ្រូបង្រៀន និងគុណភាពនាយកសាលារៀន។ ក្នុងន័យនេះ កំណែទម្រង់អប់រំនាពេលបច្ចុប្បន្ន ផ្តោតទៅលើការពង្រឹង ការគ្រប់គ្រងសាលារៀន ការពង្រឹងគុណភាពគ្រូ និងការកែលម្អការបង្រៀន និងការរៀន ដោយផ្តល់ឱ្យសាលារៀននូវស្វ័យភាពហិរញ្ញវត្ថុ និងការទទួលខុសត្រូវចំពោះលទ្ធផលសិក្សារបស់សិស្ស។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការខាងលើនេះក្នុងការអនុវត្តកំណែទម្រង់វិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំនូវស្តង់ដានេះឡើងដើម្បី តម្រូវឱ្យនាយកសាលារៀនមានគុណវុឌ្ឍិគ្រប់គ្រាន់ មានសមត្ថភាពខាងការគិតបែបយុទ្ធសាស្ត្រ និងនវានុវត្តន៍ មានភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរដ្ឋបាលសាលារៀន កម្មវិធីសិក្សា ការបង្រៀន និងការរៀនតាមបរិបទថ្មីក្នុងសតវត្សទី២១ ដើម្បីជំរុញឱ្យគណៈគ្រប់គ្រងសាលារៀនមានលទ្ធភាពអភិវឌ្ឍខ្លួនពេញមួយជីវិត មានលទ្ធភាពដោះស្រាយបញ្ហាប្រឈមថ្មីៗ ប្រកបដោយឧត្តមភាព ដោយផ្សារភ្ជាប់សាលារៀន និងសហគមន៍។

ឆ្លើយតបនឹងទិសដៅខាងលើ ក្រសួងបានរៀបចំស្តង់ដានាយកសាលារៀន ដែលមាន ៦ស្តង់ដារួមមានគម្រិតវប្បធម៌និងបទពិសោធការងារ សមត្ថភាពនិងគុណសម្បត្តិរបស់នាយកសាលារៀន បំណិនត្រិះរិះពិចារណានិងនវានុវត្តន៍ ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀននិងរៀន និងការផ្សារភ្ជាប់សាលារៀននិងសហគមន៍។ ការរៀបចំស្តង់ដានេះ ស្របតាមក្របខ័ណ្ឌសមត្ថភាពនាយកសាលារៀននៅក្នុងតំបន់ និងក្របខ័ណ្ឌច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន គោលនយោបាយស្តីពីគ្រូបង្រៀន ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន និងឧបករណ៍វាយតម្លៃនាយកសាលារៀនល្អ ដែលជាឧបសម្ព័ន្ធទី១ នៃប្រកាសលេខ ៧៦១ អយក.ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការកំណត់ គោលការណ៍ លក្ខណៈវិនិច្ឆ័យ និងនីតិវិធីនៃការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អសម្រាប់ផ្តល់ពានរង្វាន់ និងថវិកាអមពានរង្វាន់លើកទឹកចិត្តក្នុងសន្និបាតអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡាសូមថ្លែងអំណរគុណចំពោះអ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍដែលបានជួយគាំទ្រជាស្មារតី សម្ភារៈ ថវិកាក្នុងការកសាងឯកសារស្តង់ដានាយកសាលារៀនឱ្យទទួលបានជោគជ័យ។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមយ៉ាងមុតមាំថា នាយកសាលារៀន អ្នកមានបំណងធ្វើជានាយកសាលារៀន និងអ្នកពាក់ព័ន្ធនឹងខិតខំប្រឹងប្រែងបំពេញនូវគុណវុឌ្ឍិ និងសមត្ថភាពរបស់ខ្លួនឱ្យស្របតាមស្តង់ដាទាំង៦ខាងលើប្រកបដោយប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

# ស្តង់ដានាយកសាលារៀន

## ១-សេចក្តីផ្តើម

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ត្រង់គោលដៅទី៤ ស្តីពីគុណភាពអប់រំ បានកំណត់អំពីចំណុចដៅយ៉ាងយូរឆ្នាំ២០៣០ ធ្វើយ៉ាងណាបង្កើនឱ្យបាននូវការបញ្ជូនគ្រូដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ឱ្យទៅគ្រប់សាលារៀនទាំងអស់។ ផ្អែកតាមគោលដៅនេះ នាយកសាលារៀន ក៏ត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ សមត្ថភាព ភាពច្នៃប្រឌិតខ្ពស់ និងការប្រាស្រ័យទាក់ទងល្អសម្រាប់ផ្តល់សេវាអប់រំ ប្រកបដោយគុណភាព និងភាពឆ្លើយតប។

គុណភាពអប់រំគឺជាគុណភាពគ្រូបង្រៀន និងគុណភាពនាយកសាលារៀន។ ក្នុងន័យនេះ កំណែទម្រង់អប់រំនាពេលបច្ចុប្បន្ន ផ្តោតទៅលើការពង្រឹងការគ្រប់គ្រងសាលារៀន ការពង្រឹងគុណភាពគ្រូ និងការកែលម្អការបង្រៀន និងការរៀន ដោយផ្តល់ឱ្យសាលារៀននូវស្វ័យភាពហិរញ្ញវត្ថុ និងការទទួលខុសត្រូវចំពោះលទ្ធផលសិក្សារបស់សិស្ស។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការខាងលើនេះក្នុងការអនុវត្តកំណែទម្រង់ វិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំនូវស្តង់ដានេះឡើងដើម្បីតម្រូវឱ្យនាយកសាលារៀនមានគុណវុឌ្ឍិគ្រប់គ្រាន់ មានសមត្ថភាពខាងការគិតបែបយុទ្ធសាស្ត្រ និងនវានុវត្តន៍ មានភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរដ្ឋបាលសាលារៀន កម្មវិធីសិក្សា ការបង្រៀន និងការរៀនតាមបរិបទថ្មីក្នុងសតវត្សទី២១ ដើម្បីជំរុញឱ្យគណៈគ្រប់គ្រងសាលារៀនមានលទ្ធភាពអភិវឌ្ឍខ្លួនពេញមួយជីវិត មានលទ្ធភាពដោះស្រាយបញ្ហាប្រឈមថ្មីៗ ប្រកបដោយឧត្តមភាព ដោយផ្សារភ្ជាប់សាលារៀន និងសហគមន៍។

ឆ្លើយតបទៅនឹងបរិបទខាងលើ កម្ពុជាបាននឹងកំពុងធ្វើកំណែទម្រង់យ៉ាងទូលំទូលាយ និងស៊ីជម្រៅលើគ្រប់វិស័យ ពិសេសវិស័យអប់រំ យុវជន និងកីឡា ដោយបានដាក់ចេញនូវវិធានការអាទិភាពនៃកំណែទម្រង់ វិស័យអប់រំ យុវជន និងកីឡាដែលរួមមាន ៨ ចំណុច។ ដោយមើលឃើញពីវឌ្ឍនភាពរយៈពេលមួយឆ្នាំនៃការ អនុវត្តកម្មវិធីកែទម្រង់វិស័យអប់រំជាថ្មីម្តងទៀត ក្រសួងអប់រំ យុវជន និងកីឡាពង្រីកកម្មវិធីកែទម្រង់រហូតដល់ ១៥ ចំណុច ដោយឈរលើមូលដ្ឋានសសរស្តម្ភទាំង៥ ក្នុងនោះសសរស្តម្ភទី១ បានកំណត់ឱ្យអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀនដែលផ្តោតសំខាន់ និងយកចិត្តទុកដាក់លើការបង្កើនគុណវុឌ្ឍិនិងបទពិសោធបុគ្គលិកអប់រំ ការអភិវឌ្ឍវិជ្ជាជីវៈ ការរៀបចំគន្លងអាជីពគ្រូបង្រៀន និងការពង្រឹងអភិបាលកិច្ចតាមគ្រឹះស្ថានសិក្សា តាមរយៈរៀបចំស្តង់ដា និងបណ្តុះបណ្តាលនាយកសាលារៀន ផ្អែកតាមយុទ្ធសាស្ត្រទី៨ នៃគោលនយោបាយស្តីពីគ្រូបង្រៀន គឺការពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន។

ផ្អែកតាមទិន្នន័យ (EMIS, ២០១៥-២០១៦) បច្ចុប្បន្នយើងមានសាលារៀន ចំនួន ១២ ៥០៤ បើប្រៀបធៀបនឹងឆ្នាំ ១៩៨១-១៩៨២ សាលារៀនមានតែ ៣ ៨៣៥ ប៉ុណ្ណោះ។ ប៉ុន្តែ នាយកត្រឹមតែ ១១ ៣៩១នាក់ប៉ុណ្ណោះ (ទិន្នន័យ HRMS ឆ្នាំ២០១៦) ដោយសារសាលាមត្តេយ្យសិក្សាមួយចំនួនស្ថិតនៅក្នុងសាលាបឋមសិក្សា ក្នុងនោះនាយកសាលារៀនដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំនួន ២ ៧៧០ នាក់ ស្រី ១ ៦២០នាក់ ដោយមានអាយុមធ្យមត្រឹម៤៣ឆ្នាំ និងរយៈពេលបម្រើការងារជាមធ្យមត្រឹម២២ឆ្នាំ។ ចាប់ពីឆ្នាំ២០០២ មកដល់ឆ្នាំ២០១៦ នាយកនាយករងសាលារៀនដែលបានទទួលការបំប៉នលើឯកសារស្តីពីភាពជាអ្នកដឹកនាំនិងគ្រប់គ្រង និងឯកសារបំណិនវិជ្ជាជីវៈ មានចំនួន ១៦ ៩៨១នាក់ ស្រី ២ ៤៦៩នាក់ ក្នុងនោះស្ត្រី ត្រូវបានលើកកម្ពស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងកម្រិតនយោបាយ និងកម្រិតបច្ចេកទេស។

ទន្ទឹមនឹងការរីកចម្រើនខាងលើ យើងមានបញ្ហាប្រឈមមួយចំនួន ដែលទាមទារឱ្យគ្រប់អ្នកពាក់ព័ន្ធទាំងអស់ត្រូវយកចិត្តទុកដាក់ដូចជា ការអភិវឌ្ឍសមត្ថភាពនាយកសាលារៀនមួយចំនួនដែលមិនទាន់មានលក្ខណៈសម្បត្តិសំខាន់ៗសមស្រប ដោយសមត្ថភាពពួកគាត់ដែលស្ថិតនៅក្នុងបរិបទ នៃនាយកសាលារៀន គណៈគ្រប់គ្រងសាលារៀនមួយចំនួនសមត្ថភាពនៅមានកម្រិតលើការ រៀបចំផែនការ និងការដាក់ចេញនូវទិសដៅ យុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍសាលារៀន។ ការដឹកនាំ និងគ្រប់គ្រងបុគ្គលិកអប់រំ ការអភិវឌ្ឍអាជីពរបស់គ្រូបង្រៀន និងការបំពេញការងាររបស់នាយកសាលារៀនទាមទារឱ្យមានការកែលម្អ។ គិតត្រឹមឆ្នាំ២០១៦ នាយក នាយករងសាលារៀនដែលបានចូល

និវត្តន៍មានចំនួន ៦ ៤៣៨ នាក់ ទាមទារការតែងតាំងបន្ថែមថ្មី និងការអភិវឌ្ឍសមត្ថភាព ដើម្បីធានាដល់ការគ្រប់គ្រងដឹកនាំសាលារៀនឱ្យមាននិរន្តរភាព។ នាយកសាលារៀនមួយចំនួនមិនទាន់មានសមត្ថភាពគ្រប់គ្រាន់សមល្មមនឹងទំហំនៃការងារដែលត្រូវបំពេញ។ នាយកសាលារៀនមួយចំនួនទៀតមិនទាន់មានទឹកចិត្ត ឬ មានមនសិការការងារខ្ពស់នៅឡើយ។ គ្រូបង្រៀនខ្លះមានសមត្ថភាព មានមនសិការខ្ពស់ តែគាត់មិនមានចិត្តចង់ធ្វើជានាយកសាលារៀនឡើយដោយសារតែមានមូលហេតុផ្សេងៗ។ ការមិនសូវគាំទ្រ និងឱ្យតម្លៃពីមជ្ឈដ្ឋានខ្លះដល់វិស័យអប់រំ ក៏ជាមូលហេតុដ៏ធំ។ បញ្ហាទាំងអស់នេះកំពុងតែបន្សល់ទុកសម្រាប់ វិស័យអប់រំនាពេលបច្ចុប្បន្នដែលទាមទារឱ្យមានការយកចិត្តទុកដាក់ស្តារ និងអភិវឌ្ឍជាបន្ទាន់។

ស្តង់ដានាយកសាលារៀននេះ នឹងផ្តល់ឱកាសដល់នាយក និងគ្រូបង្រៀនទាំងអស់ បង្កើនចំណេះដឹងទូទៅលើស្វ័យសិក្សា សមត្ថភាពនៃការស្រាវជ្រាវ បច្ចេកវិទ្យាអប់រំ ព័ត៌មានវិទ្យា ភាសាបរទេស ចំណេះដឹងផ្នែកប្រវត្តិសាស្ត្រការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំ បំណិនវិជ្ជាជីវៈ ជំនាញអភិវឌ្ឍគំនិត ដើម្បីកែលម្អការបង្រៀននិងរៀននៅក្នុងសាលារបស់ខ្លួន ជំនាញទំនាក់ទំនងល្អជាមួយសហគមន៍ គោលនយោបាយ ផែនការ និងលិខិតបទដ្ឋានគតិយុត្តនានាពិសេសក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ច្បាប់ស្តីពីការអប់រំ។ ស្តង់ដានេះក៏កំណត់ផងដែរនូវគុណវុឌ្ឍិនាយកសាលារៀន ចាំបាច់ត្រូវមានសញ្ញាបត្របរិញ្ញាបត្រឡើងទៅ និងមានបទពិសោធការងារជាគ្រូបង្រៀន យ៉ាងតិច៥ឆ្នាំ មានសុខភាពល្អ និងសីលធម៌រស់នៅល្អ។ ស្តង់ដានេះផ្តល់ឱកាសឱ្យបុគ្គលិកអប់រំណាចង់ធ្វើនាយកត្រូវដាក់បេក្ខភាពប្រឡងប្រជែងជានាយកសាលារៀន ដោយកំណត់អាណត្តិជានាយកសាលារៀនរយៈពេល៥ឆ្នាំ និងត្រូវធ្វើការផ្លាស់ប្តូរទីកន្លែងបម្រើការងារម្តង។ នាយកសាលាត្រូវមានសិទ្ធិទទួល ឬ បដិសេធ និងបញ្ឈប់បុគ្គលិកតាមកិច្ចសន្យា និងមានសិទ្ធិលើកសំណើលើកទឹកចិត្តដល់បុគ្គលិកជាប្រចាំ មានប្រាក់ឧបត្ថម្ភទៅតាមទំហំការងារ មានការលើកទឹកចិត្តដោយគិតពីអតីតភាពការងារជានាយក និងលទ្ធផលការងារ៥ឆ្នាំឡើងស័ក្តិម្តង និងផ្តល់ឯកសណ្ឋានតាមឋានៈ។

ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើន និងបញ្ហាខាងលើ ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ ចក្ខុវិស័យរយៈពេលវែងដល់ឆ្នាំ២០៣០ និងរៀបចំស្តង់ដានាយកសាលារៀនដែលផ្តោតជាសំខាន់លើគុណវុឌ្ឍិ និង បទពិសោធការងារ ការគិតបែបយុទ្ធសាស្ត្រ និងនវានុវត្តន៍ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរដ្ឋបាលសាលារៀន ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងការរៀន ឧត្តមភាពរបស់នាយកសាលារៀន និងការផ្សារភ្ជាប់សាលារៀននិងសហគមន៍ ក្នុងគោលដៅពង្រឹងការផ្តល់សេវាអប់រំប្រកបដោយគុណភាព ភាពឆ្លើយតប និងសុខដុមនីយកម្មក្នុងអង្គភាព។

## ២-ចក្ខុវិស័យ

នាយកមានគុណវុឌ្ឍិគ្រប់គ្រាន់ សមត្ថភាពខ្ពស់ ភាពច្នៃប្រឌិតរស់រវើក និងការប្រាស្រ័យទាក់ទងល្អក្នុងការដឹកនាំគ្រប់គ្រងសាលារៀន និងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព ឆ្លើយតបទៅនឹងបរិបទនៃការអប់រំក្នុងប្រទេស តំបន់ និងពិភពលោក។

## ៣-គោលបំណង

ស្តង់ដានាយកសាលារៀននេះ មានគោលបំណងកំណត់គុណវុឌ្ឍិ និងសមត្ថភាពនាយកសាលារៀនទៅតាមប្រភេទគ្រឹះស្ថានសិក្សានីមួយៗ និងផ្លាស់ប្តូរឥរិយាបថក្នុងការអភិវឌ្ឍសមត្ថភាពស្ថាប័ន ដើម្បីគាំទ្រដល់គ្រូបង្រៀនដែលបានបំពេញការងារទៅតាមសមត្ថភាព និងទេពកោសល្យ និងផ្សារភ្ជាប់សាលារៀន និងសហគមន៍។

## ៤-គោលដៅ

- ផ្តល់ឱកាសឱ្យនាយកសាលារៀនមានគុណវុឌ្ឍិ និងសមត្ថភាពពេញលេញដើម្បីឆ្លើយតបទៅនឹងបរិបទថ្មីឆ្ពោះទៅគុណភាពអប់រំ
- ពង្រឹងស្វ័យវាយតម្លៃសាលារៀនប្រកបដោយគុណភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ
- ប្រែក្លាយសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំប្រកបដោយបំណិនក្នុងការដោះស្រាយបញ្ហាចំពោះមុខ

- បង្កើនទំនាក់ទំនងជាមួយអាជ្ញាធរ សហគមន៍ និងមាតាបិតាសិស្ស ដើម្បីអភិវឌ្ឍន៍សាលារៀនប្រកបដោយនិរន្តរភាព
- ពង្រីកសក្ដានុពលអប់រំក្នុងសាលារៀន ដោយផ្ដល់សិទ្ធិអំណាចឱ្យនាយក នាយិកាសាលារៀបចំចាត់ចែងហេដ្ឋារចនាសម្ព័ន្ធ។

## ៥-វិសាលភាព

ស្ដង់ដានេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានសិក្សាសាធារណៈទាំងអស់ ចាប់ពីនាយកមត្តេយ្យសិក្សា រហូតដល់វិទ្យាល័យ ដើម្បីធានាសមត្ថភាពដឹកនាំ និងគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ស្របតាមច្បាប់ស្ដីពីការអប់រំ។

## ៦-ស្តង់ដា

### ស្តង់ដាទី១ ៖ កម្រិតវប្បធម៌ និងបទពិសោធការងារ

នាយកសាលារៀន ត្រូវមាន៖

- កម្រិតវប្បធម៌យ៉ាងទាបបំផុតបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ឬប្រសិទ្ធផលគ្រប់គ្រាន់(នាយកល្អប្រចាំឆ្នាំណាមួយ)
- វិញ្ញាបនបត្រវិជ្ជាជីវៈនាយកសាលារៀន
- ចំណេះដឹងមូលដ្ឋាន ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ និងវប្បធម៌ទូលំទូលាយ
- ចំណេះដឹងជំនាញភាសាបរទេសអាចប្រើប្រាស់បានក្នុងការប្រាស្រ័យទាក់ទង
- បទពិសោធបំពេញការងារជាគ្រូបង្រៀនយ៉ាងតិច ៥ឆ្នាំ។

### ស្តង់ដាទី២ ៖ សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលារៀន

នាយកសាលារៀន ត្រូវមានសមត្ថភាព និងគុណសម្បត្តិដែលបង្ហាញពីភាពខ្លាំង និងប្រសិទ្ធភាពរបស់ខ្លួន ក្នុងការគ្រប់គ្រង និងបំពេញការងារឱ្យអស់ពីសមត្ថភាព និងលទ្ធភាព ដោយយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់ខ្លួនជាប្រចាំ។

នាយកដែលមានប្រសិទ្ធភាពក្នុងការគ្រប់គ្រង ត្រូវដឹកនាំដោយធ្វើជាគំរូ បង្ហាញសកម្មភាពល្អៗប្រចាំថ្ងៃ ហ៊ានបង្ហាញពីតម្លាភាព និងគណនេយ្យភាព អ្វីៗដែលបានធ្វើត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ មានមោទនភាពលើ វិជ្ជាជីវៈរបស់ខ្លួន ត្រូវបំពេញការងារឱ្យអស់ពីលទ្ធភាព និងសមត្ថភាព ចេះជ្រើសរើសចំណុចណាជាអាទិភាពមកធ្វើមុន ហ៊ានធ្វើសេចក្ដីសម្រេចចិត្តក្នុងការដោះស្រាយបញ្ហាប្រឈម បង្ហាញឥរិយាបថ ភាពជាសហគ្រិនភាព។ លើសពីនេះនាយកសាលារៀន ចាំបាច់ត្រូវអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ក្នុងនោះមានស្វ័យសិក្សា ស្រាវជ្រាវ គាំទ្រតម្លៃទស្សនវិស័យរបស់អាស៊ាន។ សូចនាករសំខាន់ៗ ៖

**២.១-ក្រមសីលធម៌វិជ្ជាជីវៈ**

- ការប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈគ្រូបង្រៀន
- ការពង្រឹងសាមគ្គីភាព
- ការគោរពវិន័យការងារ
- ការរក្សាការសម្ងាត់វិជ្ជាជីវៈ ភក្ដីភាពចំពោះអង្គភាព ចំណេះដឹងវិជ្ជាជីវៈ ការផ្ដល់តម្លៃអ្នកសិក្សា ការមិនរើសអើង ការមិនប្រើអំពើហិង្សា សីលធម៌រស់នៅល្អ ប្រកបដោយគុណធម៌ និងយុត្តិធម៌
- សុភវិនិច្ឆ័យ និងការពិគ្រោះយោបល់ផ្អែកលើភស្តុតាងជាក់ស្តែង។

**២.២-ភាពជាអ្នកដឹកនាំ**

- ចំណង់ចំណូលចិត្តក្នុងការសិក្សាស្រាវជ្រាវ ការស្វែងយល់អំពីរបកគំហើញថ្មីៗពាក់ព័ន្ធទៅនឹងការដឹកនាំ និងគ្រប់គ្រងសាលារៀន
- ការផ្ដល់ឱកាស កិត្តិយស និងតម្លៃ ដល់សហការី
- ជំនាញដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាពដោយមានការចូលរួម
- ស្វ័យវាយតម្លៃការងារប្រចាំថ្ងៃ ដើម្បីកែលម្អក្រោយពេលបំពេញការងារ (១០-១៥នាទី)
- បំណិនប្រសប់ក្នុងការកំណត់សកម្មភាពអាទិភាព ដែលត្រូវអនុវត្ត
- គំរូក្នុងការដឹកនាំ និងការប្រតិបត្តិល្អៗសម្រាប់ភាគីពាក់ព័ន្ធទាំងអស់
- ការសម្រេចចិត្តត្រឹមត្រូវ និងមានប្រសិទ្ធភាពផ្អែកតាមលក្ខខណ្ឌ តម្រូវការតាមមូលដ្ឋាន និងគោលនយោបាយជាតិជំរុញឱ្យមានការយល់ដឹងពីពហុវប្បធម៌ និងគោរពពីភាពដទៃពីគ្នា។

**២.៣-ការប្ដេជ្ញាចិត្ត**

- ឆន្ទៈក្នុងការកសាងជំនឿទុកចិត្តដល់អង្គភាព ហ៊ាននិយាយ ហ៊ានធ្វើ ហ៊ានទទួលខុសត្រូវ
- ការយល់ដឹង ស្រឡាញ់ ថែរក្សា និងការពារបរិស្ថានឱ្យបានស្អាតល្អ
- ការអត់ធ្មត់ និងចេះសម្របខ្លួនក្នុងស្ថានការណ៍លំបាក។

## ស្តង់ដារទី៣ ៖ បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍

ការគិត និងការវិភាគដោយប្រមូលភស្តុតាង ទិន្នន័យ និងស្មើជាសេណារីយោក្នុងការដោះស្រាយបញ្ហា ព្រមទាំងគិតទៅលើគំនិតថ្មីៗ ធ្វើឱ្យប្រសើរឡើងក្នុងការបំពេញការងារ។

នាយកសាលារៀនចាំបាច់ត្រូវស្វែង យល់អំពីក្របខ័ណ្ឌគតិយុត្ត តាមរយៈការអភិវឌ្ឍសមត្ថភាព ការពង្រឹងយន្តការ និងគោលការណ៍ជំរុញប្រសិទ្ធភាពការងារ ដោយមានការចូលរួម ដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវ។ សូចនាករសំខាន់ៗ ៖

**៣.១-ចក្ខុវិស័យ បេសកកម្ម គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ**

- ការយល់ដឹង និងផ្សព្វផ្សាយអំពីគោលនយោបាយ គោលការណ៍ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង
- ការយល់ដឹងអំពីទិសដៅរបស់ក្រសួង និងអភិវឌ្ឍចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន(៥ឆ្នាំ ៣ឆ្នាំ ១ឆ្នាំ)
- ការផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនដល់អ្នកពាក់ព័ន្ធក្នុងគោលដៅអនុវត្តឱ្យមានប្រសិទ្ធភាព។

**៣.២-ការអនុវត្តចក្ខុវិស័យ និងផែនការសកម្មភាព**

- ការរៀបចំបែងចែកការងារ ភារកិច្ច និងការទទួលខុសត្រូវទៅតាមសមត្ថភាពបច្ចេកទេស និងរចនាសម្ព័ន្ធ
- ការគ្រប់គ្រង និងបែងចែកធនធានក្នុងអង្គភាព (ថវិកា មនុស្ស សម្ភារៈ និងព័ត៌មាន)។

**៣.៣-ការត្រួតពិនិត្យ និងវាយតម្លៃការងារ**

- ស្វ័យវាយតម្លៃអំពីការបំពេញការងារ និងការកែលម្អ
- ការបណ្ដុះគំនិត ឆន្ទៈ មនសិការ និងការប្ដេជ្ញាចិត្តដល់បុគ្គលិកឱ្យចេះស្រឡាញ់ការងាររបស់ខ្លួន និងរបស់អង្គភាព ឬ ស្ថាប័ន
- ការអនុវត្តចក្ខុវិស័យ បេសកកម្ម គោលនយោបាយ គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តនានា
- ការសហការក្នុងការបំពេញការងារប្រកបដោយភាពរីកចម្រើន និងមានជំនឿជាក់
- ការតាមដាន ប្រមូល វិភាគទិន្នន័យ និងព័ត៌មាននានាពីប្រភពផ្សេងៗ ដើម្បីប្រសិទ្ធភាពនៃការដឹកនាំ និងគ្រប់គ្រង

- ការដោះស្រាយទាន់ពេលវេលារាល់សំណូមពរ និងបញ្ហានានាក្នុងគោលដៅកែលម្អប្រសិទ្ធភាពការងារ
- ការផ្ដល់ទិន្នន័យ និងព័ត៌មានដល់ថ្នាក់ដឹកនាំតាមឋានានុក្រម និងតាមតម្រូវការចាំបាច់។

**ស្តង់ដារទី៤ ៖ ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន**

ការគ្រប់គ្រងរដ្ឋបាលសាលារៀន ជាភារកិច្ចសំខាន់មួយរបស់អ្នកដឹកនាំក្នុងការធ្វើឱ្យប្រសើរឡើងផ្នែកគុណភាព និងប្រសិទ្ធភាពដើម្បីធ្វើការវាស់ស្ទង់ និងដោះស្រាយបញ្ហាចំពោះមុខលើការរៀបចំអង្គភាពមួយដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តនានា សំដៅធ្វើឱ្យមានការអភិវឌ្ឍលើគ្រប់ផ្នែក ដូចជា បរិស្ថាន ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ និយតភាពការងារ និងត្រួតពិនិត្យវាយតម្លៃ ការផ្ដល់សេវា ការគ្រប់គ្រងទិន្នន័យស្ថិតិបុគ្គលិក ថ្នាក់ សិស្ស ការរៀបចំផែនការសកម្មភាព និងថវិកា ដើម្បីបង្ហាញភស្តុតាងជាក់លាក់ក្នុងការអនុវត្តអ្វីដែលថ្មីរបស់នាយកសាលារៀន។ សូចនាករសំខាន់ៗ៖

**៤.១-ការគ្រប់គ្រងរដ្ឋបាល**

- ការបង្កើតវប្បធម៌ទំនាក់ទំនងរវាងគ្រូបង្រៀន និងថ្នាក់ដឹកនាំ
- ការចាត់ចែងការប្រើប្រាស់ធនធាននានាឱ្យមានប្រសិទ្ធភាព និងចំគោលដៅ
- ការដឹកនាំ និងសម្របសម្រួលការរៀបចំផែនការ និងថវិកា ដោយធ្វើវិចារណកម្មចំណាយ និងការចាត់អាទិភាពចំណាយ
- ការរៀបចំប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុប្រកបដោយតម្លាភាព គណនេយ្យភាព សុវត្ថិភាព និងភាពអាចជឿទុកចិត្តបាន
- ការរៀបចំរចនាសម្ព័ន្ធបែងចែងតួនាទី និងភារកិច្ចដល់បុគ្គលិកតាមជំនាញប្រកបដោយប្រសិទ្ធភាព
- ការរៀបចំ និងបង្កើតគណៈកម្មការ និងក្រុមប្រឹក្សានានា
- ការរៀបចំទុកដាក់លិខិតស្នាមនានា និងឯកសារគណនេយ្យ ស្របតាមគោលការណ៍ណែនាំ
- ការធ្វើប្រតិភូកម្មឱ្យមានប្រសិទ្ធភាព ដើម្បីសម្រេចគោលបំណងរបស់ផែនការយុទ្ធសាស្ត្រ
- ការបង្កើនការគ្រប់គ្រង ការដឹកនាំ និងសមិទ្ធកម្មប្រកបដោយគណនេយ្យភាព
- ការរៀបចំប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាលារៀន
- ការបង្ហាញសមត្ថភាពក្នុងការគិតប្រកបដោយការច្នៃប្រឌិត ការឆ្លុះបញ្ចាំង ការត្រិះរិះពិចារណា និងការដោះស្រាយបញ្ហា
- ការដឹកនាំអង្គប្រជុំប្រកបដោយប្រសិទ្ធភាព ដោយប្រើប្រាស់រយៈពេលខ្លី មានចំណុចពិភាក្សាច្បាស់លាស់ និងសម្រេចលទ្ធផលបានតាមការរំពឹងទុកពេលបញ្ចប់ការប្រជុំ
- ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់គ្រប់គ្រងសាលារៀន និងបណ្ដាញការងារប្រកបដោយប្រសិទ្ធភាព
- ការចែករំលែកចំណេះដឹងថ្មីៗដល់សហការីអំពីបទពិសោធល្អៗរបស់សាលាដទៃ
- ការដឹកនាំសិស្សជួយការងារសង្គម និងសហគមន៍ រួមមានការងារបរិស្ថាន អនាម័យ ចរាចរណ៍ ប្រយុទ្ធប្រឆាំងគ្រឿងញៀន កសិកម្ម បុណ្យជាតិ អន្តរជាតិ ការផ្ដល់ឈាម ការងារវប្បធម៌ សិល្បៈ ព័ត៌មាន ទេសចរណ៍ ការងារយុវជន កាយរឹទ្ធិ។

**៤.២-ការគ្រប់គ្រងបុគ្គលិក**

- ការស្វែងយល់ពីសុខទុក្ខរបស់គ្រូ និងបុគ្គលិកក្នុងសាលា ដោយសិក្សាអំពីស្ថានភាពជីវភាពរបស់គ្រូ ព័ត៌មាននានាពាក់ព័ន្ធនឹងគ្រូបង្រៀន(ប្រវត្តិ ទីកន្លែងស្នាក់នៅ ឈ្មោះ លេខទូរស័ព្ទ ចំណង់ចំណូលចិត្ត និងថ្ងៃខែឆ្នាំចូលនិវត្តន៍)
- ការលើកទឹកចិត្តអ្នកដែលមានស្នាដៃល្អ ដោយស្នើដំឡើងថ្នាក់ ឋានន្តរស័ក្តិ ផ្តល់ប័ណ្ណសរសើរ

- ការណែនាំ ដល់គ្រូបង្រៀនឱ្យចេះថែទាំសុខភាព អនាម័យ ការស្លៀកពាក់ ឥរិយាបថក្នុងការរស់នៅ និងធ្វើការងារ
- ការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនប្រកបដោយតម្លាភាព
- ការបង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀននិងបុគ្គលិកអប់រំទាំងអស់នៅក្នុងសាលាឱ្យទទួលបានការសិក្សាបន្ថែម(ជំរុញឱ្យធ្វើការស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងលើមុខវិជ្ជាបង្រៀន និងគរុកោសល្យ)
- ការលើកទឹកចិត្តឱ្យមានយេនឌ័រក្នុងការចូលរួមគ្រប់សកម្មភាព
- ការលើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀន និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។

**៤.៣-ការគ្រប់គ្រងហិរញ្ញវត្ថុ**

- ការពិនិត្យតាមដាន និងវាយតម្លៃលើលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន
- ការប្រមូល និងវិភាគទិន្នន័យ ដើម្បីរៀបចំវាយតម្លៃគម្រោងផែនការឱ្យមានប្រសិទ្ធភាព។

## ស្តង់ដាទី៥ ៖ ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងរៀន

ប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីសិក្សា ការបង្រៀន និងរៀន មិនអាចកាត់ផ្តាច់ពីតួនាទីរបស់អ្នកដឹកនាំសាលារៀនដែលជាកត្តាជំរុញដ៏សំខាន់ ធានាដល់គុណភាពក្នុងការអនុវត្តការងាររបស់គ្រូបង្រៀន។ ស្តង់ដានេះជួយនាយកសាលារៀនឱ្យទទួលបានជោគជ័យក្នុងការធ្វើឱ្យសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅ។ នាយកសាលារៀនចាំបាច់ត្រូវដឹកនាំការអនុវត្ត និងការកែលម្អកម្មវិធីសិក្សា ការបង្កើត បរិស្ថាននិងបរិយាកាសសិក្សា ការធ្វើអធិការកិច្ចនិងការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន និងការផ្តល់លទ្ធផលសិក្សា។ សូចនាករសំខាន់ៗ ៖

**៥.១-ការគ្រប់គ្រងការរៀន និងការបង្រៀន**

- ការធានាឱ្យមានសម្ភារៈសម្រាប់ដំណើរការបង្រៀននិងរៀន និងផ្តល់ឱកាសដល់គ្រូ សិស្សប្រើប្រាស់ សម្ភារៈ និងធនធានសិក្សាទាំងឡាយដោយឈរលើស្មារតីថ្លៃថ្នូរប្រឌិត និងថែរក្សា
- ការជំរុញ និងលើកទឹកចិត្តគ្រូប្រើចិត្ត-គរុកោសល្យច្បាស់លាស់ក្នុងការសម្របសម្រួលឱ្យសិស្សចេះរៀន
- ការរៀបចំធ្វើគម្រោងផែនការអធិការកិច្ចដើម្បីជួយគ្រូ និងអនុវត្តផែនការនេះឱ្យបានទៀងទាត់
- ការជំរុញគ្រូធ្វើផែនការបង្រៀន និងអនុវត្តផែនការនោះបានត្រឹមត្រូវជាប្រចាំ
- ការសង្កេតការបង្រៀនរបស់គ្រូ និងផ្តល់ព័ត៌មានត្រឡប់ប្រកបដោយការលើកទឹកចិត្ត
- ការលើកទឹកចិត្តគ្រូឱ្យបង្រៀនដល់សិស្សគ្រប់ប្រភេទដោយមិនរើសអើង
- ការជំរុញគ្រូបង្រៀនផ្តល់ការបង្រៀនឱ្យចប់កម្មវិធីសិក្សា និងស្របតាមតម្រូវការរបស់សិស្ស
- ការជំរុញគ្រូបង្រៀនឱ្យលើកទឹកចិត្តសិស្សក្នុងការស្វ័យសិក្សាជាប្រចាំ
- ការបង្កបរិយាកាសរៀនសូត្រល្អប្រសើរ ប្រកបដោយភាពរីករាយ ស្និទ្ធស្នាល និងជំនឿជាក់។

**៥.២-ការស្រាវជ្រាវ**

- ការរៀបចំក្រុមបច្ចេកទេស និងប្រជុំបច្ចេកទេសឱ្យបានទៀងទាត់
- ការចូលរួម និងជំរុញការសិក្សាស្រាវជ្រាវមេរៀន
- ការស្រាវជ្រាវ និងរិះរកវិធីសាស្ត្រល្អៗ ដើម្បីឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព។

**៥.៣-ការសហការ និងទំនាក់ទំនង**

- ការរៀបចំប្រជុំបុគ្គលិក និងសហគមន៍ក្នុងការពិនិត្យ កែលម្អ អភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សា
- ការផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃជាផ្លូវការដល់ភាគីពាក់ព័ន្ធ
- ការរក្សាបាននូវវប្បធម៌សាមគ្គីភាព សន្តិភាព និងការគោរពគ្នាទៅវិញទៅមកតាមឋានានុក្រម។

**៥.៤-ការអភិវឌ្ឍសមត្ថភាព**

- ការអភិវឌ្ឍ និងប្រើប្រាស់ធនធានសិក្សាប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ
- ការលើកទឹកចិត្តដល់គ្រូបង្រៀនដែលបំពេញការងារបានល្អ
- ការផ្តល់ឱកាសឱ្យគ្រូបង្រៀនបានទស្សនកិច្ចសិក្សានៅសាលាដែលល្អ
- ការសម្របសម្រួល និងជំរុញសកម្មភាពចែករំលែកចំណេះដឹង និងបទពិសោធទៅវិញទៅមក (បង្កើតកម្មវិធីអ្នកមានបទពិសោធច្រើនឱ្យជួយអ្នកមានបទពិសោធន៍តិច)។

**៥.៥-ការធ្វើអធិការកិច្ចផ្ទៃក្នុង**

- ការពិនិត្យតាមដាន និងវាយតម្លៃសកម្មភាព ដើម្បីកែលម្អលទ្ធផលសិក្សា
- ការវាយតម្លៃលទ្ធផលសិក្សា និងសរសេររបាយការណ៍អំពីវឌ្ឍនភាពនៃការបង្រៀន និងរៀន
- ការវាយតម្លៃចំណុចខ្លាំង និងចំណុចខ្វះខាត ដើម្បីកែលម្អលើវិធីសាស្ត្របង្រៀន។
- ការបង្កើតបរិស្ថានសិក្សាល្អ មានអនាម័យ សណ្តាប់ធ្នាប់ របៀបរៀបរយ និងគ្មានគ្រោះថ្នាក់
- ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សប្រកបដោយតម្លាភាព យុត្តិធម៌ ឱ្យបានទៀងទាត់
- ការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃ ជាប្រយោជន៍ដល់ការកែលម្អដំណើរការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព។

## ស្តង់ដារទី៦ ៖ ការផ្សារភ្ជាប់សាលារៀននិងសហគមន៍

សហគមន៍មានតួនាទីដ៏សំខាន់ក្នុងដំណើរការអភិវឌ្ឍសាលារៀន។ ទំនាក់ទំនងល្អរវាងសាលារៀននិងសហគមន៍ជាកត្តាចាំបាច់មិនអាចខ្វះបាន។ ប្រការនេះជាកម្លាំងចលករ និងជាប្រភពមិនចេះរីងស្ងួត ក្នុងការលើកកម្ពស់គុណភាពបង្រៀន រៀន និងលទ្ធផលសិក្សារបស់សិស្ស តាមរយៈ ការចូលរួមរៀបចំផែនការ ស្វែងរកធនធាន និងការពិនិត្យតាមដានវឌ្ឍនភាព ក្នុងដំណើរការអភិវឌ្ឍវិស័យអប់រំ ឱ្យមានជីវិតស្រស់បំព្រង ប្រកបដោយសុខដុមនីយកម្ម។ សូចនាករសំខាន់ៗ៖

**៦.១-អាជ្ញាធរដែនដី**

- ការបង្កើនទំនាក់ទំនងជិតស្និទ្ធ និងយូរអង្វែងជាមួយសហគមន៍ អាជ្ញាធរ មាតាបិតាសិស្ស និងអ្នកពាក់ព័ន្ធនានា ដើម្បីអភិវឌ្ឍន៍សាលារៀន
- ការដឹកនាំ និងសម្របសម្រួល ការកៀរគរធនធានពីប្រភពផ្សេងៗ ដើម្បីអភិវឌ្ឍសាលារៀន
- ការពង្រឹងការគ្រប់គ្រង និងដឹកនាំ ដោយបង្ហាញឱ្យឃើញច្បាស់អំពីផែនការ ការទទួលខុសត្រូវខ្ពស់ តម្លាភាព និងមិនប្រកាន់បក្សពួក
- ការកសាងទំនុកចិត្ត ដោយខិតខំបង្កើនសមិទ្ធផល លទ្ធផលសិក្សាល្អ គោរពឆន្ទៈរួម មានការលះបង់ មានចក្ខុវិស័យ បេសកកម្ម រចនាសម្ព័ន្ធច្បាស់លាស់។

**៦.២-មាតាបិតា**

- ការបង្កើតទំនាក់ទំនងល្អ ជាមួយមាតាបិតាសិស្ស ក្នុងការប្រមូលកុមារចូលរៀន និងលទ្ធផលសិក្សា
- ការពន្យល់ពីតម្លៃនៃការអប់រំដល់មាតាបិតាសិស្ស
- ការផ្សព្វផ្សាយរាល់សមិទ្ធផលការងាររបស់សាលា ដែលសហគមន៍បានចូលរួមអភិវឌ្ឍ។

**៦.៣-ភាគីពាក់ព័ន្ធ**

- ការកសាងបណ្តាញទំនាក់ទំនងជាមួយអ្នកឯកទេស និងអ្នកជំនាញលើគ្រប់វិស័យ ដើម្បីចូលរួមអភិវឌ្ឍការអប់រំ ក្នុងនោះមានវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យសុខាភិបាល វិស័យកសិកម្ម វិស័យឧស្សាហកម្ម សិប្បកម្ម សុវត្ថិភាពចរាចរណ៍ វិស័យវប្បធម៌ ទេសចរណ៍ ព័ត៌មាន សាសនា...

- ការបង្កលក្ខណៈងាយស្រួលដល់អ្នកពាក់ព័ន្ធចូលរួម ដោយផ្ដល់ការគាំទ្រ ការផ្ដល់កិត្តិយស និងការផ្ដល់ឱកាសចូលរួមក្នុងសកម្មភាពនានា
- ការស្ដាប់ និងទទួលយកនូវគំនិត ឬ យោបល់រិះគន់ ស្ថាបនាពីសហគមន៍ និងភាគីពាក់ព័ន្ធ។

## ៧-សេចក្ដីសន្និដ្ឋាន

ស្តង់ដានាយកសាលារៀនបានកំណត់គោលការណ៍សំខាន់ៗ រួមមាន គុណវុឌ្ឍិ បទពិសោធការងារ ការគិតបែបយុទ្ធសាស្ត្រ នវានុវត្តន៍ ភាពជាអ្នកដឹកនាំ ការគ្រប់គ្រងរដ្ឋបាលសាលារៀន ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងការរៀន ឧត្តមភាពរបស់នាយកសាលារៀន និងការផ្សារភ្ជាប់សាលារៀននិងសហគមន៍ ក្នុងគោលដៅពង្រឹងការផ្ដល់សេវាអប់រំប្រកបដោយគុណភាព ភាពឆ្លើយតប និងសុខដុមនីយកម្មក្នុងអង្គភាព។

ភាពជោគជ័យក្នុងការអនុវត្តស្តង់ដានាយកសាលារៀន គឺជាទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធទាំងអស់ ពិសេសនាយកសាលារៀនផ្ទាល់។ ស្តង់ដានាយកសាលារៀននេះជាតំណាងឱ្យចំណុចចាប់ផ្ដើមនៃទស្សនវិស័យដែលមានគោលការណ៍ច្បាស់លាស់ មានបរិយាប័ន្ន និងមានលក្ខណៈសម្របសម្រួល ដើម្បីឈានឆ្ពោះទៅរកការកសាងនាយកដែលមានស្តង់ដា ស្របតាមក្របខ័ណ្ឌសមត្ថភាពនាយកសាលារៀននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ផែនការសកម្មភាពគោលនយោបាយស្ដីពីគ្រូបង្រៀន និងឧបករណ៍វាយតម្លៃនាយកសាលារៀនល្អ។

ការអនុវត្តស្តង់ដានាយកសាលារៀនប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ អាចសម្រេចទៅបានប្រសិនបើអ្នកពាក់ព័ន្ធទាំងអស់ទទួលស្គាល់ពីតួនាទី សារៈសំខាន់ និងភាពមិនអាចខ្វះបានរបស់នាយកក្នុងការអភិវឌ្ឍសាលារៀន ព្រមទាំងផ្ដល់ការគាំទ្រគ្រប់រូបភាព ជាពិសេសធនធានថវិកា៕